# អង្គការឃែរកម្ពុជា_ប៉ៃលិន

## ផលិតកម្មផ្សិតអំបោះ

## ការគ្រប់គ្រង និង ថែទាំកញ្ចប់ផ្សិត



## គំរោងសមារណកម្មសកម្មភាពមីន

## និងសុវត្ថិភាពស្បៀង ខេត្តប៉ៃលិន

Australian Government

AusAID

care

## សារៈប្រយោជន៍នៃផលិតកម្មផ្សិតអំបោះ

- ផ្គត់ផ្គង់អាហាររូបត្ថមប្រចាំគ្រួសារ
- កាត់បន្ថយការចំណាយលើការទិញម្ហូបអាហារ
- បង្កើនប្រាក់ចំណូលបន្ថែមប្រចាំគ្រួសារ

## ការអនុវត្តន៍ផលិតកម្មផ្សិតអំបោះក្រោមការគាំទ្រពីគម្រោង

- ១.៨៤៧ គ្រួសារបានទទួលការគាំទ្រពីគម្រោង
- កសិករ ១ គ្រួសារទទួលបាន ៥០ ទៅ ១០០ កញ្ចប់
- កសិករ ៩១ ភាគរយបានទទួលផលពីផលិតកម្មផ្សិត តាមខែនីមួយ ក្នុងកំឡុងពេលផលិតកម្ម។
- ចំណូលដុលទទួលបាន ជាមធ្យម ៧.៩ ដុល្លារ ក្នុង ១ ខែ ដែលបានពីការបរិភោគ ការលក់ដូរ និង ការប្រើប្រាស់ផ្សេងៗ (សំរាប់ផ្សិត ១០០ កញ្ចប់) (ក្រោយពេលទូទាត់ពីការចំណាយផ្សេងៗ)





# តើគួរគ្រប់គ្រងផ្សិតយ៉ាងដូចម្តេចដើម្បីទទួលបានផលច្រើន និង រយៈពេលយូរ ?

## ១. ការធ្វើរោងសំរាប់ដាក់កញ្ចប់ផ្សិត

- ទីតាំងនៅកន្លែងត្រជាក់ (ក្រោមម្លប់ឈើ, លើទឹក...)
- នៅឆ្ងាយពីកន្លែងចំអិនម្ហូបអាហារ, ក្លិនស្អុយ, ទ្រុងសត្វ...





# ធ្វើរោង៖





- ត្រូវប្រកដំបូលឱ្យជិត ដើម្បីការពារភ្លៀង
- គួរធ្វើរោងផ្សិតកុំឱ្យហាប់ក្តៅ ព្រោះផ្សិតត្រូវការភាពត្រជាក់ ។
- ចូរកុំប្រើកៅស៊ូតង់ សំរាប់ប្រក ឬ ព័ទ្ធរោងផ្សិត ព្រោះវាធ្វើឱ្យ រោងផ្សិតឡើងកំដៅ
- គួរក្រាលខ្សាច់នៅក្នុងរោងដើម្បី បង្កើនភាពត្រជាក់ដល់ផ្សិត។
- រានដាក់កញ្ចប់ផ្សិត គួរមានកំពស់ ៣០ ស.ម ពីដី ។

# ការរៀបចំកញ្ចប់ផ្សិត

## មានវិធីសាស្ត្រច្រើន ដែលប្រើសំរាប់រៀបចំកញ្ចប់ផ្សិត





រៀបផ្តេកកញ្ចប់ផ្សិត ដោយបង្ហើបបាតថង់ឱ្យខ្ពស់ជាងមាត់បន្តិច

# ការស្រោចទឹក





- ត្រូវស្រោចទឹកជាប្រចាំដើម្បីឱ្យកញ្ចប់ផ្សិតមានសំណើម ( ៤-៦ ដង/១ថ្ងៃ)
- ត្រូវស្រោចទឹកលើកញ្ចប់ផ្សិតនិងមិនត្រូវឱ្យមានទឹកដក់ក្នុងថង់ផ្សិតទេ
- ត្រូវប្រើទឹកស្អាត គ្មានក្លិន សំរាប់ស្រោចកញ្ចប់ផ្សិត
- គួររៀបចំប្រព័ន្ធទុយោសំរាប់ស្រោច កាន់តែប្រសើរ
- គួរប្រើក្រណាត់គ្របលើកញ្ចប់ផ្សិតដើមរក្សាសំណើមបានយូរសំរាប់ផ្សិត

# ការប្រមូលផល



- ក្រោយពីដាក់ផ្តេកផ្សិតចំនួន ៣-៧ ថ្ងៃ ផ្សិតចាប់ផ្តើមដុះហើយក្នុងរយៈពេល ២ ថ្ងៃ វានឹងរីកធំ អាចប្រមូលផលបាន
- ពេលប្រមូលផល យើងអាចចាប់មូល ផ្សិតបន្តិចរួចទាញចេញ ពីមាត់ថង់
- គល់ផ្សិតដែលនៅជាប់ក្នុងថង់ត្រូវឆ្កឹះចេញឱ្យអស់ ព្រោះវាអាចរលួយ និងកើតមេរោគ

# បញ្ហានានា



ការកាត់មាត់ថង់កញ្ចប់ផ្សិតនឹងផ្ដល់ផលរយៈពេលខ្លី ផលតិច ។



ស្ព័រផ្សិតដុះខ្សោយបណ្ដាលមក ពីកំហុសឆ្គងពេលផលិតមេ



ផ្សិតដុះមិនល្អ ដោយសារប្រើទឹកក្រខ្វក់ស្រោច និងខ្វះអនាម័យ ។



ផ្សិតឡើងពណ៌លឿង ស្ងួត ផ្នែកខាងលើ បណ្តាលមកពីខ្វះសំណើម ។